គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

លេខ ៥០ ចេញផ្សាយថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២
No. 50 Released on July 1, 2022

និយ័តករបរធនបាលកិច្ច
Trust Regulator

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# វិធានប្រតិបត្តិការរបស់ក្រុមហ៊ុនបរធនបាល
# The Operating Rules of Trustee Company



http://www.coachkomatsu.com/shinraikankei/

យោងតាមច្បាប់ស្តីពី “បរធនបាលកិច្ច” (២០១៩), បទប្បញ្ញត្តិពាក់ព័ន្ធ និងប្រកាសលេខ ០០៣/អ.ស.ហ./ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពី “វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច” ក្រុមហ៊ុនបរធនបាលត្រូវមានវិធានប្រតិបត្តិការសមស្របដើម្បី÷

១. ចាត់ចែង គ្រប់គ្រង និងថែរក្សាសុវត្ថិភាពសាច់ប្រាក់ ឬទ្រព្យសម្បត្តិបរធនបាលកិច្ច។

២. គ្រប់គ្រងបរធនអនុលោមតាមលិខិតបរធនបាលកិច្ច គោលការណ៍ណែនាំ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣. ធានានូវភាពដាច់ដោយឡែកពីគ្នារវាងទ្រព្យសម្បត្តិបរធនបាលកិច្ច និងទ្រព្យសម្បត្តិផ្ទាល់របស់ក្រុមហ៊ុនបរធនបាល។

៤. កត់ត្រាភាពជាម្ចាស់កម្មសិទ្ធិ ឬសិទ្ធិ ដែលមានលើទ្រព្យសម្បត្តិបរធនបាលកិច្ច ចំណូលចំណាយ និងរាល់បំណុលដែលពាក់ព័ន្ធនឹងបរធនបាលកិច្ច សម្រាប់ការអនុវត្តគម្រោងផែនការនៃបរធនបាលកិច្ចនីមួយៗ។

៥. ត្រួតពិនិត្យផលប្រយោជន៍ផ្សេងៗ ដែលទទួលបានពីទ្រព្យសម្បត្តិបរធនបាលកិច្ច។

៦. បែងចែកផលប្រយោជន៍ផ្សេងៗដល់អត្ថគាហក:។

៧. ត្រួតពិនិត្យ និងទប់ស្កាត់ការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច ដែលផ្ទុយពីបញ្ញត្តិក្នុងលិខិតបរធនបាលកិច្ច គោលការណ៍ណែនាំ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងការចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដែលមានភាពមិនស្មោះត្រង់។

According to the Law on Trust (2019), relevant provisions and Prakas No. 003 dated January 26, 2022, on " Rules on the Management, Organization, and the Functioning of Trust ", trustee company must have appropriate operating rules to:

1. administer manage and safeguard the cash or assets of trust.

2. manage the trust fund in accordance with the trust instrument, guidelines, and regulations.

3. ensure the separation between the trust assets and the assets owned by the trustee company.

4. record the ownership or rights over the trust assets, revenue, expenses, and all liabilities related to the trust for the implementation of each trust plan.

5. supervise the various benefits derived from the trust assets.

6. allocate various benefits to beneficiaries.

7. supervise and prevent the management of trust assets that contradict the provisions of the trust instruments, guidelines and regulations and the dishonest management and administration of the trust assets.

**អត្ថបទ÷ ភាន់ វីរ៉ាលីន | Article: Phorn Viralynn**

**ឯកសារយោង | References:**

- ច្បាប់ស្តីពីបរធនបាលកិច្ច (២០១៩)
- ប្រកាសស្តីពីវិធានគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច (២០២២)

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.